APHR ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

# សមាជិកសភាអំពាវនាវឲ្យមានរណសិរ្សរួបរួមជាមួយសង្គមស៊ីវិល ដើម្បីទប់ទល់នឹងការគម្រាមកំហែងចំពោះប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស នៅអាស៊ីអាគ្នេយ៍




លោកជំទាវ មូរ សុខហួរ សមាជិកសភាកម្ពុជា ថ្លែងនៅក្នុងកិច្ចប្រជុំ Town Hall ជាមួយសង្គមស៊ីវិល នៅក្នុងវេទិកាប្រជាពលរដ្ឋអាស៊ាន នៅទីក្រុងឌីលី ប្រទេសទីម័រខាងកើត

ទីក្រុងឌីលី, ប្រទេសទីម័រខាងកើត, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ - កាលពីថ្ងៃម្សិលមិញ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំជាមួយតំណាងសង្គមស៊ីវិលរាប់រយនាក់ នៅប្រទេសទីម័រខាងកើត សមាជិកសភាបានព្រមានថា អនាគតនៃការការពារប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស នៅអាស៊ីអាគ្នេយ៍ ស្ថិតនៅក្រោមការគម្រាមកំហែង ហើយអ្នកតំណាងរាស្ត្រ និងសង្គមស៊ីវិល មកពីជុំវិញតំបន់ នឹងត្រូវធ្វើការជាមួយគ្នា ប្រសិនបើពួកគេចង់បន្តមានវត្តមានតទៅទៀត។

លោកជំទាវ Eva Kusuma Sundari សមាជិកសភាឥណ្ឌូនេស៊ី បានថ្លែងនៅក្នុងកិច្ចប្រជុំនេះថា "យើងត្រូវទប់ស្កាត់ការបំផ្លិចបំផ្លាញដល់ប្រជាធិបតេយ្យក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។" ដោយ

សង្កត់ធ្ងន់លើសារៈសំខាន់នៃការគម្រោមកំហែង ដែលបង្កឡើងដោយដំណើរថយក្រោយនៃប្រជាធិបតេយ្យ លោកជំទាវបានបញ្ជាក់ថា ការព្យាយាមដោះស្រាយក្តីព្រួយបារម្ភអំពីសិទ្ធិមនុស្ស ទាមទារឲ្យមានកម្រិតនៃគណនីភាព និងតំណាងពិតប្រាកដ ដែលអាចផ្តល់ដោយអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យតែប៉ុណ្ណោះ។

លោកជំទាវបានថ្លែងថា "យើងត្រូវនាំគ្នាធ្វើអ្វីគ្រប់បែបយ៉ាងដែលយើងអាចធ្វើបាន ដើម្បីធានាថា អាស៊ានប្រកាន់ខ្ជាប់នូវតម្លៃនៃប្រជាធិបតេយ្យ ពីព្រោះសម្រាប់បញ្ហាទាំងអស់របស់អាស៊ាន មានតែប្រជាធិបតេយ្យប៉ុណ្ណោះដែលជាវិធីតែមួយគត់ ដើម្បីដោះស្រាយបញ្ហាសិទ្ធិមនុស្ស។"

ការអត្ថាធិប្បាយទាំងអស់នេះ ត្រូវបានធ្វើឡើង ក្នុងខណៈពេលដែលសមាជិកសភាមកពីប្រាំបីប្រទេសបានចូលរួមក្នុងវេទិកា Town Hall ដែលរៀបចំធ្វើនៅប្រទេសទីម័រខាងកើត នៅថ្ងៃអង្គារ ដោយអង្គការសមាជិកសភាអាស៊ាន ដើម្បីសិទ្ធិមនុស្ស ដែលបានចាប់ផ្តើមវេទិកាប្រជាពលរដ្ឋអាស៊ានឆ្នាំ២០១៦ ដែលជាកិច្ចប្រជុំប្រចាំឆ្នាំដ៏ធំបំផុតនៃសង្គមស៊ីវិលមកពីតំបន់អាស៊ីអាគ្នេយ៍។

ដោយទទួលបានសំណួរពីអ្នកចូលរួមក្នុងវេទិកា សមាជិកសភាបានពិភាក្សាអំពីស្ថានភាពសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ នៅអាស៊ីអាគ្នេយ៍ ដោយបានបញ្ជាក់បង្ហាញអំពីការរីកដុះដាលនៃបញ្ហាប្រឈមដែលបំផ្លិចបំផ្លាញប្រជាធិបតេយ្យ និងផលប៉ះពាល់នៃដំណើរការធ្វើសមាហរណ៍កម្មអាស៊ាន ចំពោះប្រពលរដ្ឋក្នុងតំបន់។

លោកជំទាវ **មូរ សុខហួរ** សមាជិកសភាកម្ពុជា បានថ្លែងថា បណ្តាប្រទេសនៃអាស៊ានស្ថិតនៅលើវិសាលគមមួយ ពីបណ្តាប្រទេសដែលប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវប្រជាធិបតេយ្យតិច ឬច្រើន ទៅកាន់បណ្តាប្រទេសដែលមិនប្រកាន់នូវប្រជាធិបតេយ្យទាល់តែសោះ។ នៅចន្លោះនេះ គឺជារដ្ឋាភិបាល ដូចជាប្រទេសកម្ពុជាជាដើម ដែលមិនមានការប្តេជ្ញាចិត្តខ្លាំងដើម្បីប្រជាធិបតេយ្យ។

ដោយលើកសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមសង្គមស៊ីវិល នៅក្នុងតំបន់ លោកជំទាវបានសម្តែងនូវការទទួលស្គាល់ថា "នៅក្នុងស្ថានភាពណាមួយខាងលើ វានៅតែជាការតស៊ូចំពោះអង្គការដែលស្ថិតនៅក្នុងសហគមន៍ និងសហជីពនានា ដើម្បីលើកយកបញ្ហារបស់ពួកគេមកពិភាក្សា។"

លោកស្រី Rachada Dhanadirek អតីតសមាជិកសភាថៃ បានពិពណ៌នាអំពីស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសរបស់លោកស្រី គឺថា គណបក្សនយោបាយត្រូវបានហាមឃាត់ចំពោះការធ្វើសកម្មភាពផ្លូវការមួយចំនួន ជាហេតុសង្គមស៊ីវិលបានដឹកនាំការតស៊ូដើម្បីប្រជាធិបតេយ្យ ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ បន្ទាប់ពីពួកយោធាបានធ្វើរដ្ឋប្រហារដណ្តើមគ្រប់គ្រងអំណាច។

អ្នកចូលរួមមួយរូបមកពីសង្គមស៊ីវិលប្រទេសឡាវ ក៏បានលើកឡើងពីក្តីបារម្ភអំពីការកើនឡើងនៃកង្វះខាតនៃលំហសម្រាប់អង្គការសង្គមស៊ីវិលឯករាជ្យនៅក្នុងប្រទេសឡាវ ជាពិសេសចាប់តាំងពីការបាត់ខ្លួនរបស់សកម្មជនសង្គមស៊ីវិលដ៏សំខាន់មួយរូបឈ្មោះ Sombath Somphone កាលពីខែធ្នូ ឆ្នាំ២០១២។ តំណាងសង្គមស៊ីវិលនានាបានសម្រេចមិនប្រារព្ធវេទិកាប្រជាពលរដ្ឋអាស៊ាននៅក្នុងប្រទេស

ឡាវ ទោះជារដ្ឋាភិបាលឡាវបានក្លាយជាប្រធានអាស៊ានក៏ដោយ ដោយសារសកម្មជន និងអង្គការឯករាជ្យនានាប្រឈមនឹងការបង្ក្រាបយ៉ាងធ្ងន់ធ្ងរនៅប្រទេសនេះ។

លោកជំទាវ Mercy Barends សមាជិកសភាឥណ្ឌូនេស៊ី បានពិភាក្សាអំពីតម្រូវការចាំបាច់ក្នុងការធ្វើប្រជាធិបតេយ្យូបនីយកម្មសេដ្ឋកិច្ចអាស៊ាន ដើម្បីធានាបានថា ផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ចអាស៊ានត្រូវបានទទួលដោយទូលំទូលាយ។

លោកជំទាវបានថ្លែងថា "នៅពេលដែលយើងនិយាយអំពីសមាហរណកម្មអាស៊ាន ជាទូទៅយើងកំពុងនិយាយអំពីសមាហរណកម្មទីផ្សារសេរី។ ដូច្នេះចាំបាច់ត្រូវមានតម្រូវការបន្ទាន់មួយសម្រាប់អាស៊ាន ដើម្បីពង្រីកខិតខំប្រឹងប្រែងនៃការធ្វើសមាហរណកម្មតំបន់របស់អាស៊ាន ហើយត្រូវផ្តោតការយកចិត្តទុកដាក់ជារួមចំពោះបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋអាស៊ាន។

ជាមួយគ្នានេះ លោកជំទាវ **មូរ សុខហួរ** ក៏បានសម្តែងចេញនូវមតិស្រដៀងគ្នានេះដែរ ពាក់ព័ន្ធនឹងកំណើនសេដ្ឋកិច្ចនៅក្នុងអាស៊ីអាគ្នេយ៍ ដោយលោកជំទាវថ្លែងថា "អាស៊ាននាពេលនេះ តំណាងឲ្យសេដ្ឋកិច្ចដែលធំជាងគេទីប្រាំពីរនៅក្នុងពិភពលោក។ ប៉ុន្តែ ការរីកលូតលាស់ និងភាពរីកចម្រើន មិនបានយកប្រជាពលរដ្ឋជាស្នូលនោះទេ ពាក់ព័ន្ធនឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពចម្បងផ្សេងៗ។"

សម្រាប់អាស៊ាន ដើម្បីក្លាយជាសហគមន៍ដែលយកប្រជាពលរដ្ឋជាស្នូលពិតប្រាកដមួយបាន លោកជំទាវបានថ្លែងថា "ចាំបាច់ត្រូវធ្វើកំណែទម្រង់ប្រព័ន្ធនយោបាយ ដើម្បីផ្តល់លទ្ធភាព និងអំណាចដល់ប្រជាពលរដ្ឋអាចចូលរួមកាន់តែមានប្រសិទ្ធភាព។"

ជាការឆ្លើយតបទៅនឹងសំណួរពីអ្នកចូលរួមពីសង្គមស៊ីវិល សមាជិកសភាក៏បានពិភាក្សាអំពីតួនាទីរបស់ពួកគេក្នុងការធានាថា បណ្តារដ្ឋជាសមាជិកអាស៊ានសម្រេចបាននូវការប្តេជ្ញារបស់ពួកគេដើម្បីសិទ្ធិមនុស្សអន្តរជាតិ។

ឯកឧត្តម Teddy Baguilat សមាជិកសភាហ្វីលីពីន បានថ្លែងថា "អ្វីដែលសំខាន់គឺយើងអាចប្រើប្រាស់សមត្ថភាពនៃការត្រួតពិនិត្យរបស់យើង។ នេះគឺជាចំណុចមួយ ដែលសភានៅក្នុងប្រទេសហ្វីលីពីនខ្វះខាត។ ក្នុងនាមជាសមាជិកសភា យើងចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើតួនាទីនៃត្រួតពិនិត្យរបស់យើង ដើម្បីធានាថា ច្បាប់ត្រូវបានអនុវត្តដោយត្រឹមត្រូវ។"

លោកជំទាវ Kasthuri Patto សមាជិកសភាម៉ាឡេស៊ី បានថ្លែងថា "ក្នុងនាមជាសមាជិកសភា វាជាការងាររបស់យើងដែលត្រូវធ្វើជាសម្លេងមួយសម្រាប់អ្នកគ្មានសម្លេង និងជាសម្លេងមួយដើម្បីសិទ្ធិមនុស្ស។ វាជាលទ្ធផលសំខាន់បំផុតនៃធន្ទៈនយោបាយ។ ខ្ញុំជឿថា អាស៊ានអាចជាសហគមន៍ដែលយកប្រជាពលរដ្ឋជាស្នូល ប៉ុន្តែទាមទារឲ្យមានការខិតខំប្រឹងប្រែងពីយើងទាំងអស់គ្នា។"

សមាជិកសភាបានសម្តែងនូវក្តីសង្ឃឹមថា កិច្ចប្រជុំ Town Hall នេះ នឹងនាំមកនូវកិច្ចពិភាក្សាកាន់តែរស់រវើកដែលមានស្មោះភាពយូរអង្វែង រវាងសមាជិកសភា និងសង្គមស៊ីវិល។

លោកបណ្ឌិត Nguyen Van Tien អតីតសមាជិកសភាវៀតណាម បានថ្លែងថា "អាស៊ានអាចជាសហគមន៍ដែលយកប្រជាពលរដ្ឋជាស្នូល ប៉ុន្តែយើងត្រូវការឲ្យមានវេទិកាដូចនេះបន្ថែមទៀត ដែលអាចឲ្យសមាជិកសភានានាសិក្សាស្វែងយល់ពីអង្គការសង្គមស៊ីវិល ហើយអង្គការសង្គមស៊ីវិលក៏អាចសិក្សាស្វែងយល់ពីបទពិសោធន៍នៅក្នុងបណ្តាប្រទេសដទៃផ្សេងទៀត។"

លោកជំទាវ **មូរ សុខហួរ** បានបន្ថែមថា "បញ្ហាប្រឈម គឺគម្លាតរវាងប្រជាពលរដ្ឋអាស៊ាន និងបណ្តារដ្ឋាភិបាលនៃអាស៊ាន។ ខ្ញុំសង្ឃឹមថា កិច្ចពិភាក្សានេះអាចផ្តល់នូវគំនិតច្បាស់លាស់ចំពោះរបៀបនាំយកមតិយោបល់របស់អ្នកទៅក្នុងកិច្ចប្រជុំអាស៊ានលើកក្រោយ។"

លោកជំទាវបានថ្លែងថា "ខ្ញុំនៅតែជឿជាក់ថា នៅតែមានឱកាសច្រើនសម្រាប់ក្តីសង្ឃឹម។ ជារៀងរាល់ថ្ងៃ ខ្ញុំមើលឃើញអំណាចប្រជាពលរដ្ឋកាន់តែខ្លាំងឡើងៗ ខណៈដែលការតស៊ូកំពុងតែមានភាពពិបាកឡើងៗ។"

សមាជិកសភាដទៃផ្សេងទៀតដែលមានវត្តមាននៅក្នុងវេទិកា Town Hall រួមមាន ឯកឧត្តម Aderito Hugo da Costa ប្រធានសភានៃប្រទេសទីម័រខាងកើត និងសមាជិកសភាមីយ៉ាន់ម៉ា U Htay Kywe ។ វេទិកាប្រជាពលរដ្ឋអាស៊ាននៅក្នុងប្រទេសទីម័រខាងកើតនេះ បានបន្តរហូតដល់ថ្ងៃទី០៥ សីហា។